# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍ភ្នំពេញ**

**សំណុំរឿងសភាស៊ើបសួរ**
**លេខ ២២៩**
**ចុះថ្ងៃទី ១៥-កញ្ញា-២០២២**
**សាលដីកា**
**លេខ ៧៩ ក្រ III "ឃ"**
**ចុះថ្ងៃទី ៣០-០៩-២០២២**

## គោរពនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សភាស៊ើបសួរ បង្កើតឡើងតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧-១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកកិច្ចពិភាក្សាដេញដោលជាអសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោម៖

**សមាសភាពក្រុមប្រឹក្សា**

**ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា**

**លោក [redacted] ជាចៅក្រមប្រឹក្សា**

**លោក [redacted] ជាចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក [redacted] ជាព្រះរាជអាជ្ញា**

**ក្រឡាបញ្ជី**

**លោកស្រី [redacted] ជាក្រឡាបញ្ជី**

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងសភាស៊ើបសួរលេខ ២២៩ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ ដែលមាន៖

-ជនត្រូវចោទឈ្មោះ [redacted] **ពេជ្រតារា** ភេទស្រី អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ស្ពឺ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ដោយមានមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទមេធាវី **[redacted]ង ស៊ីឡៀង** អត្តលេខ ៩៨៧ មេធាវី [redacted] **ស្រីរនួន** អត្តលេខ២៥៥០T និងមេធាវី [redacted] **គន្ធា** អត្តលេខ ២៥០៨ T មានការិយាល័យមេធាវី អេស-អ៊ិន អេ ស្ថិតនៅអគារ J-Tower Concominium South Bkk1 ជាន់ទី៤ ផ្ទះលេខ ២៦៣ ផ្លូវលេខ៦៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

បានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ៖ **អំពើលួច និងក្លែងបន្លំ** ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំ

ដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៣៥៣ , មាត្រា ៣៥៦,មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ។

**ដើមបណ្តឹងរដ្ឋប្បវេណី ៖ ធនាគារស្ថាបនា សាខាស្រុកអង្គស្នួល-ឃុំដំណាក់អំពិល** មានអាសយដ្ឋានចុះបញ្ជីពាណិជ្ជកម្មស្ថិតនៅផ្លូវជាតិលេខ៤ ភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានលោក [redacted] **ចាន់ធីរៈ** ជានាយកសាខាស្តីទី និងជាតំណាងឱ្យធនាគារ ។

ដោយមានលោក [redacted] **សុខោ** អត្តលេខ ១៣០៣ ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី មានការិយាល័យ ក្រុមមេធាវីលីហ្គលថោន ស្ថិតនៅអគារបារាំង ជិតតុលាការកំពូល មហាវិថីសម្តេចសុធារស សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ មានជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានចូលរួមមកបម្រើការងារជាមន្ត្រីចុះកិច្ចសន្យានៅធនាគារស្ថាបនាសាខាស្រុកអង្គស្នួល ឃុំដំណាក់អំពិល ស្ថិតក្នុងភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានតួនាទីជាធារី (Teller) ។ ចាប់តាំងពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ ជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានលួចដកប្រាក់របស់អតិថិជន និងក្លែងបន្លំ ស្នាមមេដៃរបស់អតិថិជន និងក្លែងបន្លំ ស្នាមមេដៃរបស់អតិថិជនជាបន្តបន្ទាប់ សរុបមានចំនួន ២៨ ប្រតិបត្តិ សរុបជាប្រាក់មានចំនួន ៣០៧៨,២៥ (បីពាន់ចិតសិបប្រាំបីដុល្លារ ម្ភៃប្រាំសេន) ដុល្លារអាមេរិក ។ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានដកប្រាក់ពីគណនីរបស់ឈ្មោះ [redacted] ឆ្នើមវិសុទ្ធ ចំនួន ៥០០ (ប្រាំបួនរយ) ដុល្លារអាមេរិក ដោយប្រើវិធីក្លែងបន្លំស្នាមមេដៃរបស់អតិថិជនដដែល ក្រោយមកធនាគារក៏ចាប់បានទើបធ្វើកិច្ចសន្យាបញ្ឈប់ជននេះពីការងារ និងដាក់ពាក្យបណ្តឹងមកកាន់សាលាដំបូងខេត្តកណ្តាលតែម្តង ។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៦៥៤ ដកសស ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៩៧២ ដកសព/២២ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**បានឃើញ** ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល បានសម្រេចដូចខាងក្រោម៖

លើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ [redacted] ខេត្តកំពង់ស្ពឺ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ពីបទ ៖ **អំពើលួច និងក្លែងបន្លំ** ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិ មាត្រា ៣៥៣ , មាត្រា ៣៥៦,មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ។

**បានឃើញ** ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ និងសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍ លេខ ០៣៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] សុខោ ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សុំប្ដឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

**បានឃើញ** ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ និងសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍ លេខ ០៣៥ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ របស់ដើមបណ្ដឹងធនាគារស្ថាបនា ភីអិលស៊ី សុំប្ដឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

**បានឃើញ** របាយការណ៍ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ។

**បានឃើញ** សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

## នាពេលពិភាក្សាដេញដោល

-ជនជាប់ចោទឈ្មោះ [redacted] ពេជ្រតារា **វត្តមាន**

-មេធាវីការពារសិទ្ធិ(ជនត្រូវចោទ) [redacted] គន្ធា **វត្តមាន**

-មេធាវីការពារសិទ្ធិ(ជនត្រូវចោទ) [redacted] **ស្រីអូន** **វត្តមាន**

-ដើមបណ្ដឹងឈ្មោះ [redacted] **ចាន់វីរៈ** **អវត្តមាន**

-មេធាវីតំណាងឱ្យដើមបណ្ដឹង [redacted] សុខោ **វត្តមាន**

-ប្រធានក្រុមប្រឹក្សាពិនិត្យវត្តមាននិងអានរបាយការណ៍សង្ខេបរឿង។

មេធាវី [redacted] **សុខោ** ៖ ខ្លួនបានដាក់ពាក្យស្នើសុំធ្វើកោសលវិច័យដើម្បីជាប្រយោជន៍ដល់ភាគីខាងកូនក្ដីខ្លួន និងស្នើសុំលើកពេល ដើម្បីធ្វើកោសលវិច័យលើស្នាមមេដៃ ដែលមានប័ណ្ណដកប្រាក់ចំនួន ១៨ ដែលបានផ្ទៀងផ្ទាត់នៅក្នុងប្រព័ន្ធរបស់ធនាគារឃើញថាមានចំនួន ៨ ប័ណ្ណជាស្នាមមេដៃរបស់ជនត្រូវចោទជំនួសអតិថិជន ដើម្បីដកលុយ និងចំនួន ១៨ ប័ណ្ណដែលកូនក្ដីខ្លួនបានផ្ទៀងផ្ទាត់ទៅឃើញថាមិនមែនជាស្នាមមេដៃរបស់អតិថិជន និងស្នាមមេដៃរបស់ជនត្រូវចោទ ដូច្នេះមិនដឹងថាស្នាមមេដៃរបស់អ្នកណាដើម្បីដកលុយ ។ ម្យ៉ាងទៀតក្នុងចំនោម១៨ប័ណ្ណកូនក្ដីខ្លួនបានគេដើម្បីត្រួតពិនិត្យមើលចំនួនបីធំៗ ហើយបានបញ្ជាក់ថាគាត់ពុំបានដកលុយនោះទេ ។ ចំពោះឈ្មោះ [redacted] វិសុទ្ធ ជាបុគ្គលិកធនាគារដែលបានដកលុយនេះ គាត់បានឆ្លើយច្បាស់ថាមិនមែនជនជាប់ចោទគេទៅប្រាក់គាត់នោះទេ គឺពេលដែលឈ្មោះ [redacted] វិសុទ្ធ ទៅទិញសម្ភារៈអនឡាញទើបដឹងថាបាត់លុយ ដូច្នេះនៅក្នុងចំណុចទាំងនេះមានវិមតិសង្ស័យខ្ពស់លើជនត្រូវចោទ ។ ចំពោះពាក្យបណ្ដឹងដែលខ្លួនបានដាក់នៅសាលាដំបូង

ខេត្តកណ្ដាល ដោយបានលើកប័ណ្ណទាំង២៨ ប័ណ្ណ ដែលមានស្នាមមេដៃមិនប្រក្រតី ហើយដោយមានការសង្ស័យខ្ពស់ ហើយធនាគារមានការព្រួយបារម្ភដោយខ្លាចបែករឿងទៅសាធារណៈជន ដូច្នេះគាត់ត្រូវការឱ្យតុលាការចេញដីកាគាត់នឹងធ្វើការឆ្លើយតប ប៉ុន្តែតុលាការខេត្តកណ្ដាលពុំបានចេញដីកាអ្វីទាំងអស់ ហើយការស៊ើបអង្កេតរបស់ចៅក្រមស៊ើបសួរមានទាំងការដាក់បន្ទុក និងដោះបន្ទុក ប៉ុន្តែការដោះដាក់បន្ទុកគាត់ពុំបានធ្វើ ដូច្នេះហើយទើបខ្លួនស្នើសុំក្រុមប្រឹក្សាមេត្តាពិចារណាបង្គង់នីតិវិធី ដើម្បីធ្វើកោសលវិច័យ ។ នៅនីតិវិធីស៊ើបសួរខ្លួនពុំបានស្នើសុំបំពេញកិច្ចនោះទេ ។

តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាបន្តនីតិវិធី ។

មេធាវី [redacted] គន្ធា ស្នើសុំក្រុមប្រឹក្សាបន្តនីតិវិធី ។

ជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា ធ្វើកំណត់សម្គាល់ ៖ ខ្លួនសុំបដិសេធការចោទប្រកាន់មកលើរូបខ្លួន លើប័ណ្ណចំនួន២៨ ប័ណ្ណ ដោយការដាក់ ឬដកលុយ លុះត្រាតែមានការអនុញ្ញាតពីអតិថិជនទើបខ្លួនអាចដកបាន ហើយនៅពេលល្ងាចដែលត្រូវធ្វើការបិទបញ្ជីត្រូវមានការពិនិត្យមើលដោយបេឡា រាល់ប្រតិបត្តិការទាំងអស់ត្រូវមានហត្ថលេខាពីអតិថិជន ប្រធានគណនេយ្យ និងលោកនាយក [redacted] វឌ្ឍា បើសិនជាខាងស្ថាប័នចោទប្រកាន់មកលើខ្លួនចំពោះ២៨ ទិដ្ឋាការនេះមានការបាត់លុយ ដែលតាំងពីខ្លួនធ្វើការងាររហូតមកដល់បច្ចុប្បន្នពុំដែលមានបាត់លុយ លើសលុយ ឬការកេងបន្លំលុយរបស់អតិថិជនទេដែលជាក់ស្ដែងនៅពេលដែលខ្លួនបម្រើការងារមកគឺមានអូឌីតអ៊ីនធើណល ដែលបានធ្វើសវនកម្មរាល់ការបន្លំលុយអតិថិជនក្នុងស្ថាប័ន ប៉ុន្តែអ្វីដែលគាត់ចោទប្រកាន់មកលើខ្លួនដែលអង្គហេតុនេះមានទាំងអស់ គឺពុំមានការលើសលុយ បាត់លុយអ្វីនោះទេ ដែលសវនករគាត់ជាអ្នករក។ មុននឹងការមានការដកប្រាក់ជូនអតិថិជនត្រូវតែមានស្នាមម្រាមដៃ អត្តសញ្ញាណប័ណ្ណ និងមានការអនុញ្ញាតពីអតិថិជន មិនមែនចេះតែដកបាននោះទេ ហើយពុំដែលមានវិវាទអតិថិជនមកតវ៉ាដែលធ្វើអោយប៉ះពាល់ដល់ស្ថាប័ននោះទេ ។ ចំពោះបញ្ហារបស់ខ្លួនគឺមានការភ័ន្តច្រឡំការដកប្រាក់ជាមួយលោកគ្រូ វិសុទ្ធ ដែលជាការភ័ន្តច្រឡំតែប៉ុណ្ណោះ ប៉ុន្តែភ្លាមៗនោះខ្លួនបានទាក់ទងទៅគាត់តាមទូរស័ព្ទទៅសុំទោសគាត់ និងបានប្រាប់គាត់ថាខ្លួនបានដកប្រាក់គាត់ដោយមានការភ័ន្តច្រឡំ តើខ្លួនអាចដាក់ប្រាក់ជូនគាត់វិញបានដែរឬទេ ហើយគាត់ប្រាប់ថាមិនអីទេ ដោយសារយើងធ្វើការនៅក្នុងអង្គភាពនិមួយៗតែងតែមានការភ័ន្តច្រលំ ម្យ៉ាងទៀតខ្លួនបានប្រាប់ទៀតថាខាងខ្លួនត្រូវបិទបញ្ជីម៉ោងបីកន្លះ តើគាត់អាចមកដើម្បីផ្ដិតមេដៃអោយរូបខ្លួន ហើយគាត់បានប្រាប់ថាមិនអីទេគាត់នឹងមក ។ ខ្លួនសូមបញ្ជាក់ដែរថាខាងស្ថាប័នបានចោទប្រកាន់មកលើខ្លួនថាបានគេចវេះមិនបានដោះស្រាយនោះខ្លួនសូមបដិសេធដោយនៅពេលមានការចោទប្រកាន់មកលើខ្លួនខ្លួនបានទៅដោះស្រាយជាមួយលោកនាយក [redacted] វឌ្ឍា ចំនួនបីលើកដែលលើកទីមួយនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ រូបខ្លួនបានទៅជួបលោក ចំរើនតួ ដែលមានតួនាទីជាប្រធានមន្ត្រីឥណទានអោយគាត់ជួយបង្ហាញរបាយការណ៍ដែលចោទប្រកាន់មកលើខ្លួន តើអតិថិជននោះគាត់ឈ្មោះអី នៅឯណា ហើយបាត់ចំនួនប៉ុន្មាន បន្លំលុនៅពេលណា ដោយសូមឱ្យគាត់ជួយបង្ហាញរបាយការណ៍ឱ្យខ្លួនឱ្យបានច្បាស់ ប៉ុន្តែគាត់បានប្រើសម្ដីមាក់ងាយ និងចោទប្រកាន់មកលើខ្លួន ។ ចំពោះប្រាក់ចំនួន ៩០០ ដុល្លារ ខ្លួនទទួលស្គាល់ថាបានបើកច្រលំ ហើយខ្លួនបានដាក់បង្វិលទៅវិញហើយ ។ ឈ្មោះ [redacted] ផ្ទើមវិសុទ្ធ ជាមន្ត្រីឥណទាននៅស្ថាប័ន

ការដកលុយច្រឡំនេះដោយសារដំបូងគាត់ឱ្យខ្លួនដកប្រាក់ចំនួន ៥០ ដុល្លារ ហើយរូបខ្លួនក៏ច្រឡំដកប្រាក់គាត់ចំនួន ៣៥០ ដុល្លារម្តងទៀត និងមានការភ័ន្តច្រឡំម្តងទៀតដោយបានដកប្រាក់គាត់ចំនួន ៥០០ ដុល្លារទៀត ដែលប្រាក់នេះជារបស់លោក វិសុទ្ធ មិនមែនជាប្រាក់របស់ធនាគារទេ ហើយបានធ្វើការដោះស្រាយរួចហើយ ។ ចំពោះ ២៨ ប័ណ្ណនេះពុំដែលមានអតិថិជនមកប្តឹងតវ៉ានោះទេ ។ ខ្លួនធ្លាប់មានទំនាស់ជាមួយមន្ត្រីឥណទានឈ្មោះ [redacted]តួ ដែលគាត់តែងតែឱ្យខ្លួនបើកកម្ចីជូនអតិថិជនដោយគ្មានស្នាមមេដៃ ដែលមានជម្លោះចំនួន២ដង ។

មេធាវី [redacted] សុខោ ធ្វើកំណត់សម្គាល់ ៖ ទាក់ទងនឹងពាក្យថាលួច និងបន្លំ ដែលជាការពិតណាស់ដែលដំណើរការនៃលុយដែលប្រជាពលរដ្ឋយកទៅដាក់នៅធនាគារ បានន័យថាទុកអោយធនាគារមើលការខុសត្រូវប៉ុន្តែដោយឡែកគឺជនត្រូវចោទដែលជាអ្នកលួចដកប្រាក់ពីធនាគារតាមរូបភាពបន្លំស្នាមមេដៃ ដូច្នេះហើយទើបខ្លួនស្នើសុំធ្វើកោសលវិច័យ បើមិនដូច្នេះទេនឹងធ្វើអោយមានការប្រថុយប្រថានខ្ពស់ ។ ចំពោះអូឌីតមើលតែទៅលើថាមានឯកសារគ្រប់លក្ខខណ្ឌតែប៉ុណ្ណោះ ដោយពុំបានវិភាគលើស្នាមមេដៃនៅពេលនោះទេ ។ ធនាគារមានតែឈ្មោះ [redacted] ផ្ទើមវិសុទ្ធ តែម្នាក់គត់ដែលបានមកតវ៉ា តែដោយឡែកមាន ១៩ ប័ណ្ណ ដែលមានចំនួន៣ ដែលមិនដឹងថាជាស្នាមមេដៃរបស់អ្នកណា ដែលធនាគារពុំទាន់បញ្ចេញឈ្មោះ ។ ប៉ុន្តែជាក់ស្តែងមានការតវ៉ាតែឈ្មោះ [redacted] ផ្ទើមវិសុទ្ធ តែម្នាក់ប៉ុណ្ណោះ ពុំមានអតិថិជនផ្សេងទៀតនោះទេ ។

## តំណាងមហាអយ្យការសន្និដ្ឋានថា៖

**យល់ឃើញថា** បណ្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] ចាន់វីរៈ ជាតំណាងអោយធនាគារស្ថាបនា ភីអិលស៊ី និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] សុខោ ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី សុំប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សភាស៊ើបសួរសាលាឧទ្ធរណ៍ យោងតាមបញ្ញត្តិមាត្រា ២៦៨ មាត្រា ២៧០ និងមាត្រា ២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**យល់ឃើញថា** យល់ឃើញថា ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល មានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវ គប្បីតម្កល់សេចក្តីសម្រេចទុកជាបានការដដែល ។

-មេធាវី [redacted] **សុខោ** ធ្វើសេចក្តីសន្និដ្ឋាន៖ ក្នុងនាមខ្លួនតំណាងឱ្យធនាគារស្ថាបនាដោយមិនសុខចិត្តនឹងការសម្រេចរបស់ចៅក្រមស៊ើបសួរដោយសម្រេចលើកលែងការចោទប្រកាន់ ដែលតាមមាត្រា ១២៧ បានចែងថាការស៊ើបសួរមានទាំងដាក់បន្ទុក និងដោះបន្ទុក តែដោយឡែកជាក់ស្តែងខ្លួនពុំបានឃើញការស៊ើបសួរដាក់បន្ទុកណាមួយឡើយ ពិសេសគឺមិនបានចាប់អារម្មណ៍លើចំណុចដែលភាគីខាងកូនក្តីខ្លួនបានរៀបចំដាក់ប័ណ្ណដកប្រាក់ដែលបញ្ជាក់ថាមានការភ័ន្តច្រឡំ រហូតដល់មានចំណុចបញ្ជាក់ថាការភ័ន្តច្រឡំនោះ គឺមាន៨ប័ណ្ណមានស្នាមមេដៃដូចទៅនឹងស្នាមមេដៃរបស់ជនត្រូវចោទ ដែលជនត្រូវចោទបានផ្តិតមេដៃនៅពេលដែលចូលធ្វើការនៅធនាគារ នេះគឺផ្ទៀង

ផ្ទាត់តាមប្រព័ន្ធsystem របស់ធនាគារ ។ ហើយក៏មាន១៩ប័ណ្ណទៀតដែលផ្ទៀតផ្ទាត់ស្នាមមេដៃទៅដែលពុំដឹងថាជាស្នាមមេដៃរបស់អ្នកណា ហើយក៏មិនមែនជាស្នាមមេដៃរបស់ជនត្រូវចោទដែរ ដែលនៅក្នុង១៩ ប័ណ្ណនេះដែរខាងធនាគារបានសាកល្បងស្នើសុំទៅថ្នាក់លើដើម្បីតេទៅអតិថិជនធំៗថាមានបានដកលុយដែរឬទេ ដោយគាត់បានឆ្លើយថាពុំបានដកនោះទេ ។ ចំណុចមួយទៀតដែលឈ្មោះ [redacted] ផ្អែមវិសុទ្ធ ដែលជាបុគ្គលិករបស់ធនាគារគាត់បាត់លុយ៩០០ ដុល្លារដែលជនត្រូវចោទបានច្រឡំ ដែលគាត់បានបញ្ជាក់ថាគាត់តេទៅឈ្មោះ [redacted] ផ្អែមវិសុទ្ធ ប៉ុន្តែឈ្មោះ [redacted] ផ្អែមវិសុទ្ធ បានបញ្ជាក់ហើយថាពេលដែលគាត់រកទិញសម្ភារៈអនឡាញនៅថ្ងៃបន្ទាប់ទើបឃើញថាបាត់លុយគាត់ ទើបគាត់មកតវ៉ាជាមួយនឹងជនត្រូវចោទ ។ ដូច្នេះខ្លួនយល់ឃើញថាការធ្វើកោសលវិច័យលើស្នាមមេដៃជាហេតុផល និងមូលហេតុចាំបាច់បំផុត ដែលការធ្វើកោសលវិច័យនេះស្របតាមមាត្រា ១៦២ នៃក្រមនីតិវិធីផងដែរ ដើម្បីការពារការសម្រេចដោយប្រថុយប្រថានណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់កូនក្ដីខ្លួន និងប៉ះពាល់ដល់អាជ្ញាអស់ជំនុំ ម្យ៉ាងទៀតអាចប៉ះពាល់ដល់ធនាគារដ៏ទៃដែលប្រជាពលរដ្ឋទុកចិត្ត ។ ដូច្នេះសំណូមពរក្រុមប្រឹក្សាពិចារណាបង្អង់ការសម្រេច និងធ្វើកោសលវិច័យជូនកូនក្ដីខ្លួន ដើម្បីស្វែងរកការពិត ហើយនិងសុំបន្តនីតិវិធីតាមមាត្រា ២៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឱ្យមានការសម្រេចណាមួយដែលជាក់លាក់ និងយុត្តិធម៌ ។

មេធាវី [redacted] គន្ធា ធ្វើសេចក្ដីសន្និដ្ឋាន៖ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ ដែលក្នុងរឿងក្ដីនេះ ពុំមានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់មកលើកូនក្ដីខ្លួននោះទេ ដែលកូនក្ដីខ្លួនបានខិតខំបំពេញការងារ គឺមានសវនកម្មទទួលស្គាល់ថាបានបំពេញការងារបានល្អ ប៉ុន្តែដោយសារតែមានវិវាទការងារផ្ទៃក្នុងទើបមានការចោទប្រកាន់កូនក្ដីខ្លួន ដោយបង្កើតជារឿងប្ដឹងមកកូនក្ដីខ្លួន ។ ដូច្នេះខ្លួនសំណូមពរតម្កល់ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល របស់សាលាដំបូងខេត្តកណ្ដាលទុកជាបានការដដែល ។

មេធាវី [redacted] ស្រីអូន ធ្វើសេចក្ដីសន្និដ្ឋាន៖ ខ្លួនសំណូមពរក្រុមប្រឹក្សាផ្ដល់យុត្តិធម៌ជូនកូនក្ដីខ្លួន និងតម្កល់ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលរបស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការដដែល ។

ជនត្រូវចោទឈ្មោះ [redacted] ពៅច្រនារា៖ ខ្លួនសំណូមពរសូមឱ្យតុលាការជួយរកយុត្តិធម៌ និងលើកលែងការចោទប្រកាន់លើរូបខ្លួន ។

-ក្រោយពីបានស្ដាប់អំណានរបាយការណ៍
-ក្រោយពីបានស្ដាប់តំណាងមហាអយ្យការសន្និដ្ឋាន
-ក្រោយពីបានស្ដាប់កំណត់សម្គាល់របស់ជនត្រូវចោទ
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ
-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាស៊ើបសួរ យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] ចាន់វីរៈ ជាតំណាងអោយធនាគារ ស្ថាបនា ភីអិលស៊ី និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ លោក [redacted] សុខោ ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី សុំប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សភាស៊ើបសួរអាចធ្វើការពិភាក្សាដេញដោលបាន យោងតាមបញ្ញត្តិមាត្រា ២៦៨ មាត្រា ២៧០ និងមាត្រា ២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ដោយយល់ឃើញថាដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរមានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវ គប្បីតម្កល់សេចក្តីសម្រេចទុកជាបានការ គប្បីក្រុមប្រឹក្សាពិចារណា ។

៣-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្តឹង ដោយបានបញ្ជាក់ថាខាងធនាគារមានតែឈ្មោះ [redacted] ផ្ទើមវិសុទ្ធ តែម្នាក់គត់ដែលបានមកតវ៉ា ពុំមានអតិថិជនផ្សេងទៀតនោះទេ គប្បីក្រុមប្រឹក្សាពិចារណា ។

៤-តាមការពិភាក្សាដេញដោល,តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ និងតាមការពិនិត្យឯកសារដែលពាក់ព័ន្ធឃើញថា ក្នុងរឿងនេះពុំមានការតវ៉ាមកធនាគារស្ថាបនា ភីអិលស៊ី ដែលជាដើមបណ្តឹងទាក់ទងនឹងការបាត់បង់ប្រាក់ ហើយក៏ពុំមានអតិថិជនណាមកប្តឹងជនត្រូវចោទដែរ មានតែឈ្មោះ [redacted] ផ្ទើមវិសុទ្ធ ម្នាក់ដែលមកធ្វើការតវ៉ា ហើយជនត្រូវចោទបានទទួលស្គាល់ថាមានការភ័ន្តច្រឡំ និងបានធ្វើការដោះស្រាយរួចរាល់ហើយ ។

៥-ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ [redacted] **ពេជ្រតារា** ភេទស្រី អាយុ៣២ឆ្នាំ ជាតិខ្មែរ ពីបទ **អំពើលួច និងក្លែងបន្លំ** ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ ឡើយ ។

៦-ក្នុងរឿងក្តីនេះចៅក្រមស៊ើបសួរ បានលើកយកសំអាងហេតុមានលក្ខណៈត្រឹមត្រូវហើយ សភាស៊ើបសួរឯកភាពតាម ដោយពុំចាំបាច់លើកយើងសំអាងហេតុដែលមកបញ្ជាក់ទៀតនោះទេ ។

៧- ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ សម្រេចរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] សុខោ ជាមេធាវីតំណាងអោយធនាគារ ស្ថាបនា ភីអិលស៊ី និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ លោក [redacted] ចាន់វីរៈ ជា

តំណាងអោយធនាគារស្ថាបនា ភីអិលស៊ី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្អែកនឹងគតិច្បាប់។

២-តម្កល់ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ សម្រេចរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល។

៣-សាលដីកានេះ ប្រកាសជាអសាធារណៈនៅថ្ងៃសុក្រ ៥ កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted]ល , [redacted] | [redacted] |

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សុក្រ ៥ កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]